# ឯកសារទស្សនាទាន

## យុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ២០២៥ ខួបទី១១៤

## ក្រោមប្រធានបទ

## «សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប»

**"For All women and girls: Rights. Equality. Empowerment."**

### ១. សេចក្តីផ្តើម៖

យុទ្ធនាការទិវាអន្តរជាតិ ៨មីនា គឺជាព្រឹត្តិការណ៍ជាសកល ដែលមហាសន្និបាតនៃអង្គការសហប្រជាជាតិ បានប្រកាសជាទិវាស្តីពីសិទ្ធិស្ត្រីនិងសន្តិភាពពិភពលោក ចាប់តាំងពីឆ្នាំ១៩៧៧។ ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជា បានរៀបចំយុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ដើម្បីរំលឹកពីការតស៊ូទាមទារសិទ្ធិ សេរីភាព និងឆ្លុះបញ្ចាំងអំពីវឌ្ឍនភាព សមិទ្ធផល បញ្ហាប្រឈម កាលានុវត្តភាពនានា និងបង្ហាញពីការប្តេជ្ញាចិត្តនិងវិធានការវិជ្ជមាន ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រីគ្រប់រូប។

នៅឆ្នាំ២០២៥នេះ **អង្គការសហប្រជាជាតិនឹងប្រារព្ធទិវាអន្តរជាតិនារី ដើម្បីអបអរសាទរខួបទី៣០ នៃសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង (ប៉េកាំងបូក៣០)**។ សេចក្តីថ្លែងការណ៍នេះ គឺជាការប្តេជ្ញាចិត្តផ្នែកនយោបាយសម្រាប់សិទ្ធិស្ត្រី ដែលបានសម្រេចនៅក្នុងសន្និបាតនៃអង្គការសហប្រជាជាតិស្តីពីស្ត្រី លើកទី៤ នៅទីក្រុងប៉េកាំង កាលពីឆ្នាំ១៩៩៥ ដោយតំណាងរដ្ឋនិងរដ្ឋាភិបាលនៃបណ្តាប្រទេស ចំនួន១៨៩ បានដាក់ចេញនូវវិធានការគោលនយោបាយ និងផែនការសកម្មភាពនៅក្នុងវិស័យសំខាន់ៗ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនិងភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី ដែលមានជាអាទិ៍៖ ១. ស្ត្រីនិងភាពក្រីក្រ ២. ស្ត្រីនិងការអប់រំ បណ្តុះបណ្តាល ៣. ស្ត្រីនិងសុខភាព ៤. អំពើហិង្សាលើស្ត្រី ៥. ស្ត្រីនិងជម្លោះប្រដាប់អាវុធ ៦. ស្ត្រីនិងសេដ្ឋកិច្ច ៧. ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចនិងសិទ្ធិអំណាច ៨. យន្តការស្ថាប័នសម្រាប់លើកកម្ពស់ស្ត្រី ៩. សិទ្ធិមនុស្សរបស់ស្ត្រី ១០. ស្ត្រីនិងប្រព័ន្ធផ្សព្វផ្សាយ ១១. ស្ត្រីនិងបរិស្ថាន និង ១២. ក្មេងស្រី។ ការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រួមជាមួយបញ្ហាជាអាទិភាពផ្សេងទៀត ដូចជាការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យាឌីជីថល គឺជាកិច្ចការបន្ទាន់ក្នុងរយៈពេល៥ឆ្នាំខាងមុខ ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនាឆ្នាំ២០៣០។

## ២. ប្រធានបទទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥

ឆ្នាំ២០២៥នេះ ដើម្បីចូលរួមជាមួយយុទ្ធនាការរបស់អង្គការសហប្រជាជាតិ និងអបអរសាទរខួប៣០ឆ្នាំ នៃសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង (ប៉េកាំងបូក៣០) ក្រសួងកិច្ចការនារីសហការជាមួយក្រសួង ស្ថាប័ន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជននិងប្រព័ន្ធផ្សព្វផ្សាយ នឹងរៀបចំ**យុទ្ធនាការទិវានារីអន្តរជាតិ ៨ មីនា ខួបទី១១៤** ក្រោមប្រធានបទ«**សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប**» ក្នុងគោលបំណង ដើម្បី**គូសបញ្ជាក់អំពីសារៈសំខាន់នៃការទទួលបាននិងអនុវត្តសិទ្ធិ ការលើកកម្ពស់សមភាព និងការពង្រឹងភាពអង់អាចចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូបនៅកម្ពុជា**។ ប្រធានបទនេះក៏ផ្តោតសំខាន់ផងដែរ លើការលើកកម្ពស់ផលជះជាវិជ្ជមាន និងទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រជូនគ្រួសារ ពង្រឹងសហគមន៍ និងវឌ្ឍនភាពសង្គម ជំរុញកំណើនការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពសង្គម។

## ៣. វឌ្ឍនភាព បញ្ហាប្រឈម កាលានុវត្តភាព និងទិសដៅឆ្ពោះទៅមុខ

ក្នុងរយៈពេល៣០ឆ្នាំកន្លងមក បន្ទាប់ពីការអនុវត្ត**សេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង** ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល ជាពិសេសក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** កម្ពុជាសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការលើកកម្ពស់សមភាពយេនឌ័រនិងភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី តាមរយៈការដាក់ចេញនិងអនុវត្តនូវគោលនយោបាយ ផែនការសកម្មភាព កម្មវិធីជាតិ និងតាមវិស័យនៅគ្រប់កម្រិត។ ការប្តេជ្ញាចិត្តផ្នែកនយោបាយ កិច្ចសហការ និងភាពជាដៃគូរវាងក្រសួង ស្ថាប័ននិងដៃគូពាក់ព័ន្ធ ក្នុងការបញ្ជ្រាបយេនឌ័រនិងធ្វើស្ថាប័នីយកម្មយេនឌ័រនៅតាមវិស័យ និងការដាក់ចេញនូវវិធានការជាវិជ្ជមាននានានៅក្នុងរបៀបវារៈកិច្ចអភិវឌ្ឍន៍ បានធ្វើឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។ យន្តការ ស្ថាប័នជាតិ និងនៅតាមវិស័យគ្រប់កម្រិតបានរៀបចំនិងដំណើរការក្នុងការដឹកនាំសម្របសម្រួល ជំរុញ និងតាមដានការអនុវត្តការលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី។ សមិទ្ធផលសំខាន់ៗដែលសម្រេចបាន រួមមាន៖

១. ស្ត្រីនិងក្រុមគ្រួសារ បានទទួលផលពីសុខសន្តិភាព និងសុវត្ថិភាព កំណើនសេដ្ឋកិច្ច ភាពប្រសើរឡើងនូវសេវាសាធារណៈ និងគោលនយោបាយកាត់បន្ថយភាពក្រីក្រ។

២. ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ច មានអត្រាខ្ពស់នៅក្នុងតំបន់ និងដោយមានការគាំទ្រពីប្រព័ន្ធអេកូឡូស៊ី សម្រាប់សហគ្រិនភាព កាលានុវត្តភាពការងារនិងសុខុមាលភាព។

៣. កម្ពុជាឆ្ពោះទៅសម្រេចបានសមភាពយេនឌ័រ ក្នុងការអប់រំកម្រិតបឋមនិងមធ្យមសិក្សា។ យោងតាមរបាយការណ៍ឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជននិងកីឡា បានបង្ហាញថា គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ (សិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិ មានភាពកាន់តែប្រសើរទាំងការចូលរៀននិងលទ្ធផលនៃការប្រឡង)។

៤. អត្រាមរណភាពមាតាបានថយចុះគួរឱ្យកត់សម្គាល់ (ពី៤៣៧នាក់ ក្នុងឆ្នាំ២០០០ មកត្រឹម១៥៤ នាក់ក្នុង១០០០០០កំណើតរស់ ក្នុងឆ្នាំ២០២១) ដោយស្ថានភាពប្រសើរឡើងនូវសេវាថែទាំសុខភាព មាតា និងសុខភាពបន្តពូជ។

៥. អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាលើស្ត្រីពីសំណាក់ដៃគូស្និទ្ធស្នាល ក្នុងមួយជីវិតមានការថយចុះ (ពី២៥% នៅឆ្នាំ២០១៤ មកនៅត្រឹម២១% នៅឆ្នាំ២០២១)។

៦. ស្ត្រីកម្ពុជា ត្រូវបានផ្តល់តម្លៃ និងទទួលស្គាល់ នៅក្នុងសហគមន៍អន្តរជាតិ សម្រាប់ការចូលរួមថែរក្សាសុខ សុវត្ថិភាព និងសន្តិភាព កម្ពុជាជាប់ចំណាត់ថ្នាក់លេខ១ ក្នុងចំណោម ប្រទេសអាស៊ាន និងលេខ១៣ ក្នុងចំណោម១២០ប្រទេស ដែលបានបញ្ជូនទាហានជាស្ត្រីក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការ សហប្រជាជាតិ។

៧. បច្ចុប្បន្ន កម្ពុជាមានស្ត្រីជាប្រធានរដ្ឋសភា សមាជិការដ្ឋសភា ព្រឹទ្ធសភា សមាជិការាជរដ្ឋាភិបាល និងថ្នាក់ ដឹកនាំនៅតាមក្រសួង ស្ថាប័ន ស្ត្រីជាអគ្គទេសាភិបាលធនាគារជាតិ ស្ត្រីជាអគ្គសវនករជាតិ និងស្ត្រីជា អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។ នៅក្នុងរដ្ឋបាលសាធារណៈ ស្ត្រីដែលមាន តួនាទីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច (ចាប់ពីអនុប្រធានការិយាល័យរហូតដល់អគ្គនាយក) មានចំនួន**២៧%** និង ស្ត្រីជាមន្ត្រីរាជការ មានចំនួន **៤២%**។

ជាមួយនឹងវឌ្ឍនភាពនេះ កម្ពុជា ក៏ដូចជាបណ្តាប្រទេសនានា នៅមានបញ្ហាប្រឈមដែលសេសសល់និង កើតឡើងថ្មីៗពាក់ព័ន្ធការវិវត្តរបស់សេដ្ឋកិច្ចសង្គម និងភូមិសាស្ត្រនយោបាយជាសកល។ នៅក្នុងនោះ រួមទាំង កត្តា ផ្នត់គំនិតសង្គម កម្រិតនៃទិន្នន័យដែលឆ្លើយតបនឹងយេនឌ័រ វិធានការពិសេសបណ្តោះអាសន្ន រួមទាំងធនធានក្នុង ការគាំទ្រជាដើម។

**រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា** ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរ ធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបន្តកំណត់ **ការលើកកម្ពស់ សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនិងក្មេងស្រីនៅគ្រប់វិស័យជាអាទិភាព នៅក្នុងរបៀបវារៈគោល នយោបាយនិងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** តាមរយៈការពង្រឹងភាពជាពលរដ្ឋ ក្នុងសង្គមដែលមានអារ្យធ ម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន ដែលក្នុងនោះ **«ស្ត្រី គឺជាស្នូល»**។ រាជរដ្ឋាភិបាល នឹងបន្តលើក កម្ពស់សមភាពយេនឌ័រ តាមរយៈការបង្កើនការវិនិយោគលើសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេង ស្រីនៅក្នុងវិស័យសេដ្ឋកិច្ច អប់រំ សុខភាពនិងការដឹកនាំសាធារណៈ ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភយេនឌ័រ បង្ក លក្ខណៈអំណោយផលដល់ស្ត្រីក្នុងការប្រើប្រាស់សិទ្ធិលើការសម្រេចចិត្តអំពីផែនការគ្រួសារ កាត់បន្ថយភាពងាយ រងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រីនិងក្មេងស្រី និងការលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់។

នៅក្នុងនោះ **ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ ឆ្នាំ២០២៤-២០២៨** បានដាក់ចេញនូវ **អភិក្រមបរិវត្តកម្មយេនឌ័រ**[1] ដោយផ្តោតលើការពង្រឹងយន្តការបញ្ជ្រាបយេនឌ័រនៅគ្រប់កម្រិត ការធ្វើស្ថាប័នីយកម្មថវិកាឆ្លើយតបយេនឌ័រ ការពង្រឹងភាពជាអ្នកដឹកនាំរបស់ស្ត្រីនិងក្មេងស្រី ការធ្វើបរិវត្តកម្មផ្នត់គំនិតយេនឌ័រ និងការពង្រឹងការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងបន្តទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងពង្រឹងភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី តាមរយៈកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដូចខាងក្រោម៖

- លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- អនុវត្តរបៀបវារៈនិងផែនការសកម្មភាពជាតិ ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ
- លើកកម្ពស់កិច្ចគាំពារសង្គមដែលឆ្លើយតបនឹងយេនឌ័រ ការងារសមរម្យនិងកន្លែងដែលមានមេត្រីភាពសម្រាប់ស្ត្រី និងការថែទាំសុខភាពឆ្ពោះទៅកម្មវិធីគ្របដណ្តប់ជាសកល សំដៅធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានដោយសមធម៌។
- ពង្រឹងភាពអង់អាចដល់ស្ត្រីក្នុងសេដ្ឋកិច្ចឌីជីថល សហគ្រិនភាព ការអភិវឌ្ឍជំនាញ សេដ្ឋកិច្ចគិតគូរពីសុខុមាលភាព អភិវឌ្ឍន៍បៃតង ការប្រែប្រួលអាកាសធាតុ ព្រមទាំងភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចប្រកបដោយបរិយាបន្ន។

កិច្ចការទាំងនេះ ចាំបាច់ត្រូវការការចូលរួម កិច្ចសហការ និងភាពជាដៃគូពីគ្រប់តួអង្គ និងដៃគូពាក់ព័ន្ធ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ក្នុងការចូលរួមពន្លឿនវឌ្ឍនភាព និងដាក់ចេញនូវវិធានការនានា ដើម្បីឈានទៅសម្រេចបាន ដូចការកំណត់នៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ និងស្របតាមសេចក្តីថ្លែងការណ៍ទីក្រុងប៉េកាំង របស់អង្គការសហប្រជាជាតិ។

## ៤. សកម្មភាពគន្លឹះៗ នៃយុទ្ធនាការ ឆ្នាំ២០២៥

១. ផ្សព្វផ្សាយព្រះរាជសារ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត តាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម។

២. គណៈប្រតិភូនារី ចូលក្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះបរមរាជវាំង។

[1] អភិក្រមបរិវត្តកម្មយេនឌ័រ ( Gender Transformative Approach ) គឺជាដំណាក់កាលទី៣ នៃក្របខ័ណ្ឌបញ្ជ្រាបយេនឌ័រ (ដំណាក់កាលទី១. ការយល់ដឹងយេនឌ័រ និង ដំណាក់កាល ទី២. ការឆ្លើយតបយេនឌ័រ)

៣. គណៈប្រតិភូនារី ចូលជួបសម្តែងការគួរសម និងរាយការណ៍ អំពីវឌ្ឍនភាពរបស់ការងារនារី ជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានព្រឹទ្ធសភា។

៤. គណៈប្រតិភូនារី ចូលជួបសម្តែងការគួរសម និងរាយការណ៍ អំពីវឌ្ឍនភាពនៃការងារនារី ជូន**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានរដ្ឋសភា។

៥. ប្រារព្ធពិធីអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** នៅវិមានសន្តិភាព។

៦. **រៀបចំព្រឹត្តិការណ៍សាធារណៈ៖ កម្មវិធីបើកទូលាយទីសាធារណៈ** (Public Open Space Event) ជាមួយមហាជន និងយុវជន នៅទីធ្លាទីប្រជុំជន ផ្សារទំនើប សាលារៀន និងសាកលវិទ្យាល័យ កម្មវិធីប្រគុំតន្ត្រី ជាមួយមហាជននៅទីសាធារណៈ និងចងបដាពាក្យស្លោកតាមមហាវិថីនិងទីសាធារណៈនានា។

៧. រៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៤ នៅតាមក្រសួង ស្ថាប័នរដ្ឋ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សានានា។

៨. **យុទ្ធនាការឌីជីថល៖** ផលិតនិងផ្សព្វផ្សាយមាតិកានិងសារខ្លីៗ របស់ថ្នាក់ដឹកនាំស្ត្រីនិងក្មេងស្រីឆ្នើម និងមានប្រជាប្រិយភាពក្នុងសង្គម និងកម្មវិធីតាមបណ្តាញសង្គមនានា ។

៩. ផលិតនិងផ្សព្វផ្សាយព្រឹត្តប័ត្រនារីរតនៈលេខពិសេស ក្រោមប្រធានបទ «**សិទ្ធិ សមភាព និងភាពអង់អាចចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប**» ។

## ៥. ដៃគូពាក់ព័ន្ធ

ក្រសួងកិច្ចការនារី សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល គ្រឹះស្ថានសិក្សា អ្នកសារព័ត៌មាន និងសហគមន៍នានា ដើម្បីក្លាយជាចលនានិងកម្លាំងរួមគ្នានៅគ្រប់កម្រិត និងគ្រប់មធ្យោបាយ ក្នុងការរៀបចំយុទ្ធនាការជាតិនេះឱ្យបានទូលំទូលាយ និងជះឥទ្ធិពលវិជ្ជមានជាអតិបរមា។

## ៦. លទ្ធផលរំពឹងទុក និងសូចនាករសមិទ្ធកម្ម

- កម្រិតបុគ្គល ថ្នាក់ដឹកនាំ គ្រួសារ សហគមន៍ និងស្ថាប័នសាធារណៈ និងឯកជន ដែលបានអបអរសាទរ អំពីសិទ្ធិ តួនាទី និងសមិទ្ធផលរបស់ស្ត្រីនិងក្មេងស្រីនៅក្នុងគ្រួសារ ស្ថាប័ន សហគមន៍ និងសង្គម រួមទាំងឆ្លុះបញ្ចាំងពីបញ្ហាប្រឈម កាលានុវត្តភាព និងការប្តេជ្ញាចិត្តសម្រាប់ទិសដៅបន្ត

- ការកើនឡើងនូវការយល់ដឹង ការប្តេជ្ញាចិត្ត និងការគាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា
- ការលើកកម្ពស់ភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី ក្នុងការដឹកនាំសហគមន៍ និងសហគ្រាសរបស់ពួកគេ
- ការពង្រឹងបណ្តាញ និងភាពជាដៃគូសម្រាប់កិច្ចការសមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រីនិងក្មេងស្រី

## ៧. សេចក្តីសន្និដ្ឋាន

ការប្រារព្ធយុទ្ធនាការទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥នេះ នៅកម្ពុជា ក្រោមប្រធានបទ **«សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រីនិងក្មេងស្រីគ្រប់រូប»** ជាយុទ្ធនាការជាតិ ដើម្បីអបអរសាទរនូវវឌ្ឍនភាពនិងសមិទ្ធផលរបស់ស្ត្រី ឆ្លុះបញ្ចាំងលើមេរៀនបទពិសោធន៍ បញ្ហាប្រឈម កាលានុវត្តភាព និងលើកឡើងនូវទិសដៅអាទិភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវសកម្មភាពជាក់លាក់ និងវិធានការជាវិជ្ជមាននានា ដើម្បីឆ្ពោះទៅធ្វើឱ្យសង្គម ដែលមានបរិយាបន្ន និងសមភាពសម្រាប់ទាំងអស់គ្នា។

## ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖


*ក្រសួងកិច្ចការនារី*
*ផ្លូវទ្រុងមាន់ ភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ ភ្នំពេញ*
*លេខទូរស័ព្ទ/ទូរសារ៖* (+៨៥៥) ១២ ៦១៥ ២៩៩/ ៧៨ ៥៤៦ ៥៧៥
*អ៊ីម៉ែល៖* cabinet@mowa.gov.kh
*គេហទំព័រ៖* www.mowa.gov.kh
*ហ្វេសប៊ុក៖* www.facebook.com/mowa.gov.kh